ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

**Kingdom of Cambodia**

Nation Religion King

ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល

Ministry of Industry, Mines and Energy

No ៤៩៦ ឧរម. ប្រក

រាជធានីភ្នំពេញ ថ្ងៃទី ០៥ ខែ កក្កដា ឆ្នាំ២០០៥

# ប្រកាស

## ស្តីពី

## ការធ្វើប្រតិភូកម្មអំណាចជូនមន្ទីរឧស្សាហកម្ម រ៉ែ និងថាមពល ខេត្ត-ក្រុង

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៥ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ស្តីពីការប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល
- បានឃើញអនុក្រឹត្យលេខ ៣៥ អនក្រ-បក ចុះថ្ងៃទី ២៦ ខែ មេសា ឆ្នាំ ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល
- បានឃើញអនុក្រឹត្យ ស្តីពីការបង្កើតអនុគណៈកម្មាធិការវិនិយោគ ខេត្ត-ក្រុង លេខ ១៥ ដល់ ៣៨ អនក្រ បក ចុះថ្ងៃទី ០៩ ខែ កុម្ភៈ ឆ្នាំ ២០០៥
- បានឃើញលិខិតលេខ ៨៣៤/០៥ ក.អ.ក ចុះថ្ងៃទី ២១ ខែ មីនា ឆ្នាំ ២០០៥ របស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ស្តីពីការធ្វើវិសហមជ្ឈការអំណាចជូនមន្ទីរ អង្គភាពក្រោមឱវាទ ខេត្ត-ក្រុង

## សម្រេច

**ប្រការ ១:** ធ្វើប្រតិភូកម្មអំណាចជូនមន្ទីរឧស្សាហកម្ម រ៉ែ និងថាមពល ខេត្ត-ក្រុង នូវសិទ្ធិសម្រេចពាក់ព័ន្ធដល់ការចេញលិខិតអនុញ្ញាត អាជ្ញាបណ្ណ័ និងការយល់ព្រមនៅក្នុងទ្រង់ទ្រាយ ក្នុងការចុះបញ្ជីសំណើស៊ីវិនិយោគរបស់ក្រុមហ៊ុនថ្មីដែលជាគំរោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ និងមានទុនវិនិយោគទាបជាង ២ លានដុល្លាអាមេរិក។ ៤

ប្រការ ២: អនុលោមតាមច្បាប់ស្តីពីការគ្រប់គ្រងអាជីវកម្មធនធានរ៉ែ ច្បាប់អគ្គិសនី និងគោលនយោបាយជាតិស្តីពីការផ្គត់ផ្គង់ទឹកស្អាត និងអនាម័យ ចំពោះគំរោងវិនិយោគក្នុងវិស័យរ៉ែ ថាមពល និងទឹកស្អាត ត្រូវមានការឯកភាពជាគោលការណ៍ពីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ជាមុនសិន មុននឹងគំរោងទាំងនេះត្រូវបានស្នើសុំចុះបញ្ជីនៅអនុគណៈកម្មាធិការវិនិយោគ ខេត្ត-ក្រុង ឬក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា។

ប្រការ ៣: ចំពោះវិស័យឧស្សាហកម្ម មន្ទីរឧស្សាហកម្ម រ៉ែ និងថាមពល ខេត្ត-ក្រុង ត្រូវចេញលិខិតអនុញ្ញាតដល់គំរោងវិនិយោគដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ជាបន្ទាន់ បន្ទាប់ពីបានចុះបញ្ជីវិនិយោគរួច និងត្រូវផ្តល់ឯកសារពាក់ពន្ធ័នឹងគំរោងទាំងនេះមកក្រសួង ដើម្បីក្រសួងមានមូលដ្ឋានក្នុងការចេញប្រកាសជាស្ថាពរ។

មន្ទីរឧស្សាហកម្ម រ៉ែ និងថាមពល ខេត្ត-ក្រុងទាំងអស់ ត្រូវទទួលយកប្រកាស និងអាជ្ញាបណ្ណ័ ពីក្រសួងជំនួសមុខអោយអ្នកស្នើសុំវិនិយោគ។

ប្រការ ៤: ចំពោះសិប្បកម្ម និងគំរោងវិនិយោគដែលស្ថិតនៅក្រៅក្របខណ្ឌ័ការងាររបស់អនុគណៈកម្មាធិការវិនិយោគ ខេត្ត-ក្រុង និងគំរោងដែលស្ថិតក្នុងបញ្ជីអវិជ្ជមាននៃអនុក្រឹត ស្តីពីការអនុវត្តន៍ច្បាប់ស្តីពីច្បាប់វិសោធនកម្មនៃច្បាប់វិនិយោគនៃព្រះរាជាណាចក្រកម្ពុជា ត្រូវអនុវត្តតាមបទបញ្ញត្តិ និងនីតិវិធីស្របតាមខ្លឹមសារនៃអនុក្រឹតលេខ ១២ អនក្រ ចុះថ្ងៃទី ០៤ ខែ មិថុនា ឆ្នាំ ១៩៩១ ស្តីពីការគ្រប់គ្រងឧស្សាហកម្មតូច និងសិប្បកម្ម និងប្រកាស សេចក្តីណែនាំ ឬលិខិតបទដ្ឋានដែលមានជាធរមាន។

ប្រការ ៥: មន្ទីរឧស្សាហកម្ម រ៉ែ និងថាមពល ខេត្ត-ក្រុង ត្រូវដំណើរការងារតាមសិទ្ធិសម្រេចក្នុងនាមក្រសួងដែលបានប្រគល់ជូនក្នុងក្របខណ្ឌ័ការងារអនុគណៈកម្មាធិការវិនិយោគខេត្ត-ក្រុង ស្របតាមសេចក្តីណែនាំលំអិត ដែលជាឧបសម្ពន្ធ័នៃប្រកាសនេះ។ ៤

ប្រការ ៦: អគ្គនាយកដ្ឋាន នាយកដ្ឋាននៃទីស្តីការក្រសួងត្រូវធ្វើការបណ្តុះបណ្តាលដល់មន្ទីរឧស្សាហកម្ម រ៉ែ និងថាមពល ខេត្ត-ក្រុង ដើម្បីធានាអោយដំណើរការនៃយន្តការនេះប្រព្រឹត្តិទៅមានភាពរលូន និងប្រសិទ្ធភាពខ្ពស់។

ប្រការ ៧: មន្ទីរឧស្សាហកម្ម រ៉ែ និងថាមពល ខេត្ត-ក្រុង ត្រូវធ្វើរបាយការណ៍ប្រចាំខែមកក្រសួងដើម្បី ក្រសួងមានមូលដ្ឋានសំរាប់ធ្វើការបូកសរុប រៀបចំគោលនយោបាយ ផែនការយុទ្ធសាស្រ្ត និងធ្វើរបាយការណ៍ជូនរាជរដ្ឋាភិបាល។

ប្រការ ៨: អគ្គនាយកដ្ឋាន នាយកដ្ឋាន មន្ទីរឧស្សាហកម្ម រ៉ែ និងថាមពល ខេត្ត-ក្រុង ត្រូវអនុវត្តប្រកាសនេះអោយមានប្រសិទ្ធភាពខ្ពស់ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។ [illegible]

ចំលងជូន:

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យ សម្តេចនាយករដ្ឋមន្ត្រី សហប្រធាន "ក.អ.ក"
- ខុទ្ទកាល័យ សម្តេចក្រុមព្រះ សហប្រធាន "ក.អ.ក"
- សាលាខេត្ត-ក្រុង
- ឯកសារ-កាលប្បវត្តិ

ស៊ុយ_សែម